# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០២ អនក្រ

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការសំរបសំរួល កម្មវិធីធនធានធម្មជាតិនិងបរិស្ថាននៅកម្ពុជា ក្នុងក្របខ័ណ្ឌជំនួយរបស់ប្រទេសដាណឺម៉ាក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ របស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងឯកសារកម្មវិធីធនធានធម្មជាតិនិងបរិស្ថាន ឆ្នាំ ២០០១-២០០៥ ដែលបានចុះហត្ថលេខា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលដាណឺម៉ាក កាលពីថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការសំរបសំរួលកម្មវិធីធនធានធម្មជាតិ និងបរិស្ថាននៅកម្ពុជា ក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍នៃប្រទេសដាណឺម៉ាក ដែលមានសមាសភាព ដូចខាងក្រោម ÷

| | |
|---|---|
| ១- ឯកឧត្តម ឈឿន យ៉ាណារ៉ា អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- អនុរដ្ឋលេខាធិការនៃក្រសួងបរិស្ថាន | អនុប្រធាន |
| ៣- អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- អនុរដ្ឋលេខាធិការនៃក្រសួងផែនការ | សមាជិក |
| ៥- អនុរដ្ឋលេខាធិការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៦- អនុរដ្ឋលេខាធិការនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- អនុរដ្ឋលេខាធិការនៃក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៨- អនុរដ្ឋលេខាធិការនៃក្រសួងសាធារណៈការនិងដឹកជញ្ជូន | សមាជិក |
| ៩- អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១០- អនុរដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១- តំណាងស្ថានទូតដាណឺម៉ាក់ | សមាជិក |

**ប្រការ២** ៖ គណៈកម្មាធិការសំរបសំរួលកម្មវិធីធនធានធម្មជាតិនិងបរិស្ថាននៅកម្ពុជា ក្នុងក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍នៃប្រទេសដាណឺម៉ាក មានភារកិច្ចដូចខាងក្រោម ៖

- ទទួលខុសត្រូវក្នុងការសំរបសំរួលការអនុវត្តន៍កម្មវិធីធនធានធម្មជាតិនិងបរិស្ថាន ដើម្បីធានាអោយរាល់សកម្មភាពទាំងឡាយនៃកម្មវិធីនេះ បានដំណើរការស្របនឹងអាទិភាពរបស់រាជរដ្ឋាភិបាល
- ផ្តល់អនុសាសន៍នានា ដើម្បីជំរុញអោយការរៀបចំគំរោងថ្មីៗបន្ថែមទៀត អាចប្រព្រឹត្តទៅបានតាមផែនការការងារនៃកម្មវិធីធនធានធម្មជាតិនិងបរិស្ថាន
- ពិនិត្យ ផ្តល់អនុសាសន៍ និងអនុម័តលើរបាយការណ៍ស្តីពីការអនុវត្តន៍កម្មវិធីប្រចាំឆមាស
- ចូលរួមកិច្ចប្រជុំត្រួតពិនិត្យកម្មវិធីរួមប្រចាំឆ្នាំ និងកិច្ចប្រជុំពិគ្រោះយោបល់កំរិតបច្ចេកទេសប្រចាំឆ្នាំ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលដាណឺម៉ាក
- សហការជាមួយក្រសួងបរិស្ថាន ដើម្បីសំរបសំរួលជាមួយអ្នកផ្តល់ជំនួយផ្សេងៗទៀតដែលធ្វើសកម្មភាពក្នុងវិស័យធនធានធម្មជាតិ និងបរិស្ថាន ។

**ប្រការ ៣** ៖ គណៈកម្មាធិការសំរបសំរួលកម្មវិធីធនធានធម្មជាតិនិងបរិស្ថាន ត្រូវប្រជុំរៀងរាល់ឆមាស ស្របនឹងកិច្ចប្រជុំពិគ្រោះយោបល់កំរិតបច្ចេកទេសប្រចាំឆ្នាំ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលដាណឺម៉ាក និងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ហើយអាចប្រជុំផ្សេងៗទៀត ក្នុងករណីចាំបាច់ ។

**ប្រការ៤** ៖ គណៈកម្មាធិការសំរបសំរួលកម្មវិធីធនធានធម្មជាតិនិងបរិស្ថានមានលេខាធិការដ្ឋាន ដែលមានទីស្នាក់ការនៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហើយប្រើប្រាស់រចនាសម្ព័ន្ធមានស្រាប់របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការឧបត្ថម្ភបច្ចេកទេសអំពី ការិយាល័យសំរបសំរួលធនធានធម្មជាតិ និងបរិស្ថាននៃប្រទេសដាណឺម៉ាក សំរាប់កិច្ចការប្រចាំថ្ងៃរបស់ខ្លួន ។ លេខាធិការដ្ឋាននេះ ត្រូវបំពេញភារកិច្ចតាមការកំណត់របស់គណៈកម្មាធិការសំរបសំរួលកម្មវិធីធនធានធម្មជាតិនិងបរិស្ថាន ។ មន្ត្រីបំរើការងារក្នុងលេខាធិការដ្ឋាន គឺជាមន្ត្រីរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬជាបុគ្គលិកដែលបំពេញការងារតាមកិច្ចសន្យា ។

**ប្រការ ៥** ៖ គណៈកម្មាធិការសំរបសំរួលកម្មវិធីធនធានធម្មជាតិនិងបរិស្ថាន មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដោយឡែក សំរាប់រាល់លិខិតផ្លូវការរបស់ខ្លួន ។

**ប្រការ ៦** ៖ ចំពោះការអនុវត្តន៍គំរោងនិមួយៗ ដែលជាសមាសធាតុនៃកម្មវិធីធនធានធម្មជាតិនិងបរិស្ថាន ក្រសួងឬស្ថាប័នឬអាជ្ញាធរទទួលខុសត្រូវនិមួយៗអាចចេញសេចក្តីប្រកាសបង្កើតគណៈកម្មការគ្រប់គ្រង និង សំរបសំរួលគំរោងរបស់ខ្លួន ។ សមាសភាព និងភារកិច្ចនៃគណៈកម្មការនេះ នឹងកំណត់ដោយ សាមីក្រសួង ឬស្ថាប័ន ក្រោយពីបានពិភាក្សានិងឯកភាពជាមួយភាគីដាណឺម៉ាករួចមក ។

**ប្រការ៧** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ៧ " ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*